# ផ្សាយដំណឹងល្អជាថ្មី

ការផ្សាយដំណឹងល្អនឹងមានជោគជ័យ ឬក៏បរាជ័យគឺអាស្រ័យទៅលើសេចក្ដីពិតនៃការមានព្រះជន្មរស់ឡើងវិញ ។ ប្រសិនបើព្រះយេស៊ូវមិនបានមានព្រះជន្មរស់ពីសុគតឡើងវិញ នោះមានន័យថា យើងគ្មានដំណឹងល្អដើម្បីនឹងចែកចាយនោះឡើយ៖ ១) អំពើបាប និងសេចក្ដីស្លាប់នៅមានអំណាច ២) យើងកំពុងថ្វាយបង្គំព្រះដែលស្លាប់ និងកំពុងតែប្រឈមមុខនឹងភាពពុករលួយ ៣) ហើយគ្រីស្ទបរិស័ទវេទនាលើសជាងមនុស្សទាំងអស់ទៅទៀត ពីព្រោះយើងត្រូវបានគេបោកប្រាស់ ហើយគួរឲ្យអាណិតណាស់។ មួយវិញសោត ប្រសិនបើការមានព្រះជន្មរស់ឡើងវិញគឺជាការពិត នោះគ្រីស្ទបរិស័ទគ្រប់ៗរូបគួរតែជំរុញចិត្តខ្លួនក្នុងការផ្សាយដំណឹងល្អនោះដោយ

សេរី និងអំណារដ៏ខ្លាំងក្លា។

ក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៥:១២-២០ សាវ័ក ប៉ុល បានវែកញែកថា ចំពោះគ្រីស្ទបរិស័ទ រាល់គ្រប់អ្វីៗទាំងអស់គឺរំពឹងលើសេចក្តីពិតនៃការមានព្រះជន្មរស់ឡើងវិញ។ ខាងក្រោមនេះគឺជាអត្ថន័យយ៉ាងចំៗទាក់ទងទៅនឹងការផ្សាយដំណឹងល្អ៖

**១. ដោយសារការមានព្រះជន្មរស់ឡើងវិញគឺជាការពិត ការប្រកាសដំណឹងល្អនឹងបង្កើតផលផ្លែ និងជំនឿដែលនឹងនាំឲ្យមានជីវិត។**

ដោយសារការមានព្រះជន្មរស់ឡើងវិញ មនុស្សស្លាប់នឹងរស់ឡើងវិញតាមរយៈពាក្យពេចន៍។ នេះគឺជាការអស្ចារ្យនៃការប្រកាសដំណឹងល្អ។ ការប្រកាសដំណឹងល្អមិនគ្រាន់តែបង្កើតឲ្យមានផលផ្លែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតឲ្យមានជំនឿដែលនាំឲ្យមានជីវិតអស់កល្បជានិច្ចទៀតផង។ ការផ្សាយដំណឹងល្អគឺមិនមែនជាការឥតប្រយោជន៍ ការគ្មានផលផ្លែ ទទេស្អាត ហើយនិងគ្មានលទ្ធផលឡើយ។ ហេតុអ្វី? ពីព្រោះព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ កំពុងគង់ខាងស្តាំព្រះហស្តនៃព្រះជាម្ចាស់ ហើយក៏កំពុងត្រាស់ហៅមនុស្សឲ្យមកឯទ្រង់តាមរយៈការធ្វើទីបន្ទាល់ដោយប្រើប្រាស់ពាក្យពេចន៍របស់យើង។

ចូរផ្សាយដំណឹងល្អអំពីព្រះយេស៊ូវ ពីព្រោះព្រះជាម្ចាស់នឹងប្រើប្រាស់ដំណឹងល្អនេះដើម្បីនាំឲ្យមានជីវិតថ្មី។

**២. ដោយសារការមានព្រះជន្មរស់ឡើងវិញគឺជាការពិត ដូច្នេះយើងអាចធ្វើជាតំណាងរបស់ព្រះជាម្ចាស់បានយ៉ាងត្រឹមត្រូវ។**

ប្រសិនបើព្រះយេស៊ូវមិនបានមានព្រះជន្មរស់ពីសុគតឡើងវិញទេ នោះមានន័យថា គ្រីស្ទបរិស័ទគឺជាអ្នកធ្វើទីបន្ទាល់ដ៏ខុសឆ្គង៖ នោះ «ឈ្មោះថាយើងខ្ញុំជាស្មរបន្ទាល់ក្លែងក្លាយពីព្រះវិញ ដ្បិតយើងខ្ញុំបានធ្វើបន្ទាល់ពីព្រះថាទ្រង់បានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញហើយ តែបើពួកស្លាប់មិនរស់ឡើងវិញមែន នោះប្រាកដជាទ្រង់មិនបានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញពិត» (១កូរិនថូស ១៥:១៥)។ ដោយសារការមានព្រះជន្មរស់ឡើងវិញគឺជាការពិត ដូច្នេះយើងអាចប្រកាស និងធ្វើជាតំណាងរបស់ព្រះជាម្ចាស់ទៅកាន់ពិភពលោកនេះដែលកំពុងវង្វេងហើយស្លាប់។

លោកអ្នកមិនមែនជាអ្នកលក់ដែលពូកែវោហារ ឬក៏ជាអ្នកបោកប្រាស់គេទេ។ លោកអ្នកមានការអនុញ្ញាត និងការបញ្ជូនឲ្យចេញទៅផ្សាយពីព្រះអាទិករនៃចក្រវាល។ លោកអ្នកអាច ហើយក៏គួរនិយាយដោយមានចិត្តម៉ឺងម៉ាត់ ចិត្តស្រឡាញ់ ភាពស្មោះត្រង់ និងការទទូចអង្វរទៅកាន់អស់អ្នកដែលមិនទាន់ជឿឲ្យពួកគាត់ទទួលជឿ។ លោកអ្នកគួរមានការទាក់ទាញចិត្ត និងមានចិត្តអាណិតពេលដែលលោកអ្នកផ្សាយដំណឹងល្អ ប៉ុន្តែស្រាប់តែពេលនោះដែរ លោកអ្នកក៏គួរមានចិត្តស្មោះត្រង់ដ៏ជ្រាលជ្រៅផងដែរ ពីព្រោះព្រះជាម្ចាស់បានបញ្ជូនលោកអ្នកឲ្យមកធ្វើជាទីបន្ទាល់របស់ទ្រង់ចំពោះកូនចៀមដែលបានបាត់បង់។

**៣. ដោយសារការមានព្រះជន្មរស់ឡើងវិញគឺជាការពិត នោះអំពើបាបរបស់លោកអ្នកត្រូវបានអត់ទោសហើយ។**

ប្រសិនបើការមានព្រះជន្មរស់ឡើងវិញមិនបានកើតឡើងទេ នោះមានន័យថា លោកអ្នកត្រូវបានទទួលការថ្កោលទោសឲ្យធ្លាក់នរកជារៀងរហូត៖ «ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្តីជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ» (១កូរិនថូស ១៥:១៧)។ ដោយសារការមានព្រះជន្មរស់ឡើងវិញ អំពើបាបរបស់លោកអ្នកត្រូវបានអត់ទោសនៅឯឈើឆ្កាង។ ត្រូវបានសម្រេច ទទួលការវាយត្រា និងការអះអាង។ គ្មានអ្វីមួយអាចមកបង្វែរនូវអ្វីដែលព្រះគ្រីស្ទបានធ្វើនៅឯឈើឆ្កាងឡើយ។

តើការសន្យាមួយនេះអាចណែនាំយើងពីការផ្សាយដំណឹងល្អជាថ្មីម្តងទៀតយ៉ាងដូចម្តេចទៅ? យើងផ្សាយដំណឹងល្អតាមសេរីភាព និងការដឹងគុណ។ លោកអ្នកអាចនឹងប្រកាសអំពីព្រះយេស៊ូវដោយមានអំណរ ពីព្រោះមេរោគដែលនឹងសម្លាប់លោកអ្នក—អំពើបាប—ត្រូវបានទទួលការព្យាបាលយ៉ាងអស់កល្បជានិច្ចហើយ។ លោកអ្នកមានអភ័យឯកសិទ្ធិក្នុងការចែកចាយការព្យាបាលដល់អស់អ្នកដែលនឹងស្តាប់លោកអ្នក។ គ្មានការស្តីបន្ទោស និងភាពអាម៉ាស់ទៀតឡើយ។ លោកអ្នកបានទទួលការអត់ទោសហើយ។ ព្រះលោហិតរបស់ព្រះយេស៊ូវមានអំណាចអាចអត់ទោសបាបណាមួយក៏បានដែរ។ ព្រះអង្គបានបង់ថ្លៃលោះអំពើបាបរបស់លោកអ្នកហើយ។

## ៤. ដោយសារការមានព្រះជន្មរស់ឡើងវិញគឺជាការពិត រាល់អស់អ្នកណាដែលស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់នៅយ៉ាងអស់កល្បជានិច្ច។

សាវ័ក ប៉ុល បានកត់ត្រាចុះក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៥:១៨ «ហើយអស់អ្នកដែលបានដេកលក់ទៅក្នុងព្រះគ្រីស្ទ គេបានត្រូវវិនាសហើយ»។ ប្រសិនបើព្រះគ្រីស្ទមិនបានមានព្រះជន្មរស់ឡើងវិញ នោះគ្មានបុគ្គលណាម្នាក់អាចមានសង្ឃឹមបានឡើយ។ គ្រប់គ្នានឹងស្លាប់ វិនាស ហើយនិងរងទុក្ខយ៉ាងអស់កល្បជានិច្ចដាច់ចេញពីព្រះជាម្ចាស់។ ដោយសារការមានព្រះជន្មរស់ឡើងវិញ ដូច្នេះអស់អ្នកណាដែលស្លាប់ក្នុងព្រះគ្រីស្ទនឹងមានជីវិតយ៉ាងអស់កល្បជានិច្ច។ អស់អ្នកណាដែលទទួលជឿលើ ហើយដើរតាមព្រះគ្រីស្ទ នោះពួកគាត់នឹងនៅជាមួយទ្រង់ជារៀងរហូត។ គ្មានសេចក្តីស្លាប់ណាដែលអាចនឹងនៅជាយូរអង្វែងនោះឡើយ។ «ឱសេចក្តីស្លាប់អើយ ទ្រនិចឯងនៅឯណា សេចក្តីស្លាប់អើយ ជ័យជម្នះរបស់ឯងនៅឯណា» (១កូរិនថូស ១៥:៥៥)។

ដូច្នេះ យើងអាចប្រកាសក្តីសង្ឃឹមដ៏នៅអស់កល្បជានិច្ចនេះ៖ ចូរទុកចិត្តលើព្រះគ្រីស្ទ ហើយនៅជាមួយនឹងព្រះអង្គយ៉ាងអស់កល្បជានិច្ច។ លោកអ្នកអាចនិយាយយ៉ាងចំៗជាមួយអស់អ្នកដែលកំពុងស្លាប់លើគ្រែគាត់។ លោកអ្នកអាចមានទំនុកចិត្តត្រង់ថា អស់អ្នកដែលលោកអ្នកស្រឡាញ់ដែលបានស្លាប់មិនមានការរងទុក្ខទៀតឡើយ។ អស់អ្នកដែលជាកម្មសិទ្ធិរបស់ព្រះគ្រីស្ទនឹងរស់នៅយ៉ាងអស់កល្បជានិច្ច។

## ៥. ដោយសារការមានព្រះជន្មរស់ឡើងវិញគឺជាការពិត យើងអាចរស់នៅក្នុងជីវិតដែលគួរឲ្យចង់បាន។

ប្រសិនបើការមានព្រះជន្មរស់ឡើងវិញមិនបានកើតឡើងទេ នោះមានន័យថា ជីវិតគ្រីស្ទបរិស័ទគឺជាជីវិតដែលគួរឲ្យពេញទៅដោយទុក្ខព្រួយ និងក្តីអាណិត៖ «បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត» (១កូរិនថូស ១៥:១៩)។ ដោយសារការមានព្រះជន្មរស់ឡើងវិញ គ្រីស្ទបរិស័ទអាចរស់នៅក្នុងជីវិតដែលគួរឲ្យចង់បាន។ ការស្គាល់ព្រះយេស៊ូវគ្រីស្ទ—ក្នុងការសុគត និងការមានព្រះជន្មរស់ឡើងវិញ—គឺជាការប្រសើរលើសអ្វីៗទាំងអស់នៅក្នុងចក្រវាលនេះ។ ត្រូវហើយ សូម្បីតែក្នុងការរងទុក្ខ។ ត្រូវហើយ ទោះបើគេប្រហារជីវិតយើងដោយកាត់ក្បាលក៏ដោយ ឬក៏ជិះជាន់យើង ឬក៏ចាត់ទុកយើងជាអ្នកតូចតាច។ ត្រូវហើយ ទោះបើគេរាប់យើងថាជាមនុស្សដែលមិនចេះគិតឲ្យទូលាយ ចំឡែក ឬក៏ជាអ្នកកាន់សាសនាដ៏ខុសគេក៏ដោយ។ យើងអាចលើកឡើងដូចសាវ័ក ប៉ុល «ហើយខ្ញុំក៏រាប់គ្រប់ទាំងអស់ទុកដូចជាខាតដែរ ដោយព្រោះសេចក្តីដែលប្រសើរជាង គឺដោយស្គាល់ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃខ្ញុំ» (ភីលីព ៣:៨)។ យើងអាចច្រៀងឲ្យអស់ពីចិត្ត «ខ្ញុំបានសម្រេចចិត្តដើរតាមព្រះយេស៊ូវ»។

លោកអ្នកអាចមានទំនុកចិត្តយ៉ាងម៉ឺងម៉ាត់ត្រង់ថា ពាក្យពេចន៍ដែលលោកអ្នកនិយាយនឹងផ្តល់ជីវិតយ៉ាងពេញបរិបូរណ៍ ហើយនៅអស់កល្បជានិច្ច។ លោកអ្នកមានចម្លើយដែលសមហេតុសមផលលើសគេទាំងអស់លើសំណួរអំពីជីវិត។ ឥឡូវនេះ លោកអ្នកអាចមានអំណរក្នុងក្តីសង្ឃឹមដ៏នៅអស់កល្បជានិច្ចដែលព្រះជាម្ចាស់បានញែកទុកសម្រាប់លោកអ្នក។ លោកអ្នកអាចសន្យាថា ជីវិតដ៏ខ្លីនេះទំនងជាមិនស្រួលទេ—លោកអ្នកទំនងត្រូវ

លះបង់ជាច្រើន ហើយក៏ទំនងជាត្រូវរងទុក្ខ—ប៉ុន្តែ ព្រះគ្រីស្ទផ្តល់ក្តីសង្ឃឹមដ៏រស់ កេរ្តិ៍មរតកនៅអនាគត ក្តីអំណរដែលពាក្យពេចន៍មិនអាចពណ៌នាបាន ហើយជាចុងក្រោយគឺក្តីសង្គ្រោះសម្រាប់ព្រលឹងលោកអ្នក (១ពេត្រុស ១:៣-៩)។ ទាំងអស់គឺស័ក្តិសមណាស់។

ហេតុដូច្នេះ ខណៈពេលដែលថ្ងៃបុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញបានមកដល់ ចូរពិចារណាលើកណ្ឌគម្ពីរ ១កូរិនថូស ១៥:៥៨ «បានជាបងប្អូនស្ងួនភ្ងាអើយ ចូរកាន់យ៉ាងខ្ជាប់ខ្ជួន ដោយឥតរង្គើ ទាំងធ្វើការព្រះអម្ចាស់ ឲ្យបរិបូរជាដរាបចុះ ដោយដឹងថា ការដែលអ្នករាល់គ្នាខំប្រឹងធ្វើក្នុងព្រះអម្ចាស់ នោះមិនមែនឥតប្រយោជន៍ទេ»។ សេចក្តីអធិស្ឋានរបស់លោកអ្នកសម្រាប់អស់អ្នកបាត់បង ការសន្ទនាដែលលោកអ្នកមានដោយចេតនាអំពីប្រធានបទខាងឯព្រលឹងវិញ្ញាណ និងការដែលលោកអ្នកព្យាយាមបង្កើតទំនាក់ទំនងដោយក្តីស្រឡាញ់ជាមួយនឹងអស់អ្នកដែលមិនស្គាល់ព្រះយេស៊ូវ ទាំងអស់នោះគឺមិនមែនឥតប្រយោជន៍ឡើយ។ ចូរនៅឲ្យខ្ជាប់ខ្ជួន។ គ្មានអ្វីដែលយើងធ្វើសម្រាប់ព្រះអង្គគឺជាការឥតប្រយោជន៍ឡើយ។ ដូច្នេះ ចូរបន្តក្នុងការផ្សាយដំណឹងល្អ។

ចូរអនុញ្ញាតឲ្យសេចក្តីពិតនៃការមានព្រះជន្មរស់ឡើងវិញ ណែនាំជាថ្មី ជំរុញ ហើយលើកទឹកចិត្តភាពឆេះឆួល និងក្តីស្រឡាញ់របស់លោកអ្នកក្នុងការផ្សាយដំណឹងល្អ។ បើព្រះជាម្ចាស់សព្វព្រះហឫទ័យ សូមឲ្យព្រះអង្គប្រទានអំណរដល់លោកអ្នកក្នុងការណែនាំនរណាម្នាក់ឲ្យស្គាល់ព្រះយេស៊ូវជាលើកដំបូងនៅថ្ងៃបុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញនេះ។

**ចំណាំ៖ យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ**

**និពន្ធដោយ៖ លោកគ្រូ Steven Lee**
**បកប្រែដោយ និងកែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ទេព រ៉ូ និងលោកស្រី ឡូញ ស្រីរ៉ុង**
**ដកស្រង់ខ្លះៗចេញពី www.thegospelcoalition.org ដោយមានការអនុញ្ញាត។**